**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** ......................១៣១......................**ក.ប**/ប្រ.ក

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការសម្រាប់ដោះស្រាយករណីពលករទេសន្តរប្រវេសន៍ខ្មែរ ដែលទើបវិលត្រឡប់មកពីព្រះរាជាណាចក្រថៃឡង់ដ៍

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការសម្រាប់ដោះស្រាយករណីពលករទេសន្តរប្រវេសន៍ខ្មែរ ដែលទើបវិលត្រឡប់មកពីព្រះរាជាណាចក្រថៃឡង់ដ៍ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | **អ៊ិត** | **សំហេង** | រដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម | **ពេជ** | **សោភ័ន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម | **អ៊ុំ** | **មាន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤-ឯកឧត្តម | **ហ៊ុយ** | **ហានសុង** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៥-ឯកឧត្តម | **សាត** | **សមុទ្រ** | អនុរដ្ឋលេខាធិការ | សមាជិក |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

| | | | |
|---|---|---|---|
| ៦-ឯកឧត្តម | **ម៉ុក ប៉ាន់** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧-ឯកឧត្តម | **ហ៊ូ ខុឌ្ឍី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨-ឯកឧត្តម | **ចាប ឫទ្ធី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៩-ឯកឧត្តម | **ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១០-ឯកឧត្តម | **សេង សក្ដា** | អគ្គនាយកការងារ | សមាជិក |
| ១១-ឯកឧត្តម | **ឡៅ ហ៊ីម** | អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | សមាជិក |
| ១២-ឯកឧត្តម | **ហុង ជឿន** | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ១៣-លោក | **អ៊ុក សមវិទ្យា** | នាយកបេឡាជាតិរបបសន្តិសុខសង្គម | សមាជិក |
| ១៤-លោក | **ហែម ម៉ុននី** | ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | សមាជិក |
| ១៥-លោក | **ឡេង តុង** | ប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ១៦-លោក | **ឃិន ចន្ថា** | ប្រធាននាយកដ្ឋានគ.ក.អ.ប.វ | សមាជិក |
| ១៧-លោក | **សុខខុន ដាវីដ** | ប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារ | សមាជិក |
| ១៨-លោក | **ហាំង តុលា** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៩-លោក | **ហៀង វាសនា** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២០-លោក | **គង់ ធារ័ត្ន** | ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| **២១-ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្តទាំង២៥** | | | សមាជិក |

**ប្រការ ២.-**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-សហការសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការដឹកជញ្ជូនពលករទេសន្តរប្រវេសន៍ខ្មែរត្រឡប់ទៅស្រុកកំណើតវិញ

-សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការគ្រប់គ្រងទិន្នន័យពលករទេសន្តរប្រវេសន៍ខ្មែរដែលភាគីថៃបញ្ជូនមកវិញ

-ទំនាក់ទំនងជាមួយភាគីថៃក្នុងការសម្របសម្រួលដល់ការបញ្ជូនពលករទេសន្តរប្រវេសន៍ខ្មែរ ដោយមនុស្សធម៌ស្របតាមគោលការណ៍ច្បាប់អន្តរជាតិ និងសិទ្ធិមនុស្ស

-ធ្វើការសិក្សាស្រាវជ្រាវអំពីតម្រូវការរបស់ពលករទេសន្តរប្រវេសន៍ខ្មែរ ដែលទើបត្រឡប់មកពីប្រទេសថៃឡង់ដ៍ និងលើកសំណើជូនរាជរដ្ឋាភិបាលនូវសំណូមពរ និងវិធានការអន្តរាគមន៍នានា

-អប់រំណែនាំពលករទេសន្តរប្រវេសន៍ខ្មែរយល់អំពីនីតិវិធីទៅធ្វើការងារនៅបរទេសដោយស្របច្បាប់ និងបញ្ហាប្រឈមនៅបរទេស

-ផ្តល់សេវាព័ត៌មានការងារ និងព័ត៌មានស្តីពីការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ

-ខិតខំដោះស្រាយការចុះឈ្មោះ និងការរកការងារធ្វើជូនពលករទេសន្តរប្រវេសន៍ខ្មែរ ដែលទើបត្រឡប់មកពីប្រទេសថៃឡង់ដ៍ឱ្យស្របតាមមុខជំនាញវិជ្ជាជីវៈ

-បំពេញភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់ប្រធានគណៈកម្មការ។

**ប្រការ ៣.-**

គណៈកម្មការនេះមានលេខាធិការដ្ឋានមួយ សម្រាប់ធ្វើជាសេនាធិការក្នុងការបំពេញការងារ ដោយមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តម | **សេង សក្ដា** | អគ្គនាយកការងារ | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៣-ឯកឧត្តម | **ឡៅ** | **ហ៊ីម** | អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | អនុប្រធាន |
| ៤-ឯកឧត្តម | **ហុង** | **ជឿន** | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | អនុប្រធាន |
| ៥-លោក | **គឹម** | **អឿន** | អគ្គនាយករងអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | សមាជិក |
| ៦-លោក | **ទៀវ** | **ម៉ាក់តែល** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៧-លោក | **គឹម** | **ចំរើន** | ទីប្រឹក្សាអមក្រសួង | សមាជិក |
| ៨-លោក | **ខុយ** | **រិទ្ធ** | នាយខុទ្ទកាល័យ | សមាជិក |
| ៩-លោក | **ហាំង** | **តុលា** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១០-លោក | **ឡេង** | **តុង** | ប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ១១-លោក | **ឃិន** | **ចន្ថា** | ប្រធាននាយកដ្ឋានគ.ក.អ.ប.វ | សមាជិក |
| ១២-លោក | **គង់** | **ធារ័ត្ន** | ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ១៣-លោក | **គឹម** | **កែវរស្មី** | ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ នៃទ.ជ.ម.ក | សមាជិក |
| ១៤-លោក | **ស្រ៊ុន** | **ចន្ថុល** | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១៥-លោក | **ជួប** | **ណារ៉ាត់** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | សមាជិក |
| ១៦-លោក | **ម៉េង** | **ហុង** | នាយករងបេឡាជាតិរបបសន្តិសុខសង្គម | សមាជិក |
| ១៧-កញ្ញា | **ឃុន** | **ច័ន្ទកញ្ញា** | មន្ត្រីទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនមានភារកិច្ចអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងមហាផ្ទៃ
- សាលារាជធានីភ្នំពេញ
- សាលាខេត្តពាក់ព័ន្ធ
- គ្រប់ក្រសួង ស្ថាប័ន អង្គភាព ពាក់ព័ន្ធ
- គ្រប់អង្គភាពក្រោមឱវាទក្រសួង

"ដើម្បីជូនជ្រាប"-

- ដូចក្នុងប្រការ ១ និង ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ